រៀមច្បងជាអ្នកកំសាក យុវជនជាអ្នកកម្ពាច

សេរីការ : មហាវិថីគ្មានទ្វារ រាបើកច្រកឱ្យអស់ផ្លូវតូចៗចូលបាន

បុរាណភាសិតខ្មែរមួយចារឹក ជាគតិថា : « ទំពាំង ស្ពង ឫស្សី », វាមានន័យប្រហែលនឹងប្រជាកំនិតមួយ គននាថា « ស្លឹកឈើជ្រុះមិនឆ្ងាយពីគល់ »។ ទីមួយ វាជារូបភាព ឱ្យដម្រៅ នូវការទំនាក់ទំនង នៃអន្តរជំនាន់, ចំណែកទី២វិញ វាជាកម្រាស នៃកំនិត បញ្ជាក់ នូវប្រតិព័ទ្ធជានិរន្ត ចំពោះប្រភព នៃកំណើត។ ដូច្នេះ កំនិតទាំងពីរនេះ វាបង្ហាញ នូវឫទ្ធានុភាព នៃថាវរភាពរបស់ប្រភពមូលដ្ឋាន ដែលជាប្រភព ជាអ្នកឱ្យកំណើតផង និង រក្សាកិរ្តិ៍ផង។ មែនពិត ប្រជាជាតិខ្មែរ មានប្រភពមូលដ្ឋានច្បាស់លាស់ ហៅថា « អារ្យធម៌មហានគរ » ដែលជាមោទនភាពអស់កាលជានិច្ច របស់ប្រជាពលរដ្ឋ, តែតាំងពីយូរយារមកហើយ មេរៀនគតិ របស់រៀមច្បង ដែលទុកជាគំរូល្អបរ សំរាប់យុវជន ដែលអាចយកមកធ្វើជា « ការ:ដោយមេត្រីភាព » វាស្ទើរគ្មានទាល់តែសោះ។ គំរូល្អបរនោះ បើសិនជាមាន គឺវាជាអំណាច នៃរៀមច្បង ដែលយុវជនស្តាប់ឱវាទដោយសកម្ម ដែលវាខុសពី អំណាចកំហិត ដែលគេស្តាប់បង្ហាប់ដោយធ្នើចក្នែក, ដ្បិតការស្តាប់ឱវាទ វាផ្អែកលើ វិស្សាសភាព។ ការមានការទុកចិត្តគ្នានេះឯង ដែលវាង្វះ នាំឱ្យយុវជន គ្មានជំនឿទៅលើរៀមច្បង។ ម្យ៉ាងទៀត គុណសម្បត្តិ នៃរៀមច្បងខ្មែរ តាំងតែពី

រៀមច្បងជាអ្នកកំសាក យុវជនជាអ្នកកម្ពាច

ឆ្នាំ ១៩៧៩ មក វាគ្មានអាការ ជាគំរូ នៃស្នាដៃល្អ និង គុណធម៌ ដែលគេទុកជា « សោភណ នៃបេះដូង » ដល់យុវជននោះឡើយ ដែលអាចគិតក្រែងបានថា ជាគុណវិបត្តិ តែម្តង។

ដូចយ៉ាង កាលរៀមច្បង ពួកគាត់រស់នៅ ក្នុងរបបយោធាយួន កាន់កាប់កម្ពុជា (១៩៧៩-១៩៨៩) ពួកគាត់លះបង់ចោលសិទ្ធិ ខ្លួន ជាពលរដ្ឋ ជាម្ចាស់ស្រុក ដើម្បីរស់រស់។ ពេលកាលនោះ គាត់ អាចលើលយកកាល:ទេស:បន្ទរបន្ទយ ដែលតម្រូវឱ្យពួកគាត់ រស់នៅ ក្នុងលក្ខខណ្ឌ ដែលវាមិនអាចឱ្យពួកគាត់ បង្ហាញ នូវ អត្តសញ្ញាណ ជាខ្មែរម្ចាស់ស្រុក និង ជាពលរដ្ឋពេញសិទ្ធិនៅស្រុក ខ្មែរ។ តែការរស់នៅបែបនេះ វាពិតជាអាចរក្សាសុខអាត្មា តែ មិនបានទុកកេរ្តិ៍ ពីរយ៉ាងដ៏សំខាន់ ដល់យុវជន គឺ : សេរីភាព និង គំរូល្អ។ ការតស៊ូ ដែលរៀមច្បង បានធ្វើពីពេលកន្លង វាជា ការបង្ហាញ នូវមាគ៌ា ដល់យុវជន សំរាប់ធ្វើក្នុងវេលានេះ។ គឺ ដោយសារស្នាដៃ នៃរៀមច្បងនោះហើយ ដែលយុវជន មិនត្រឹម តែមានសេរីភាពប៉ុណ្ណោះទេ គឺថែមទាំងស្គាល់ដឹង នូវរបៀបថា ត្រូវធ្វើបែបណា ដើម្បីរក្សា នូវសេរីភាពនោះ កុំឱ្យបាត់បង់បាន ដែលខ្មែរ តែងនិយាយថា « ធ្វើតាមរៀមច្បងយើង ព្រោះគាត់ ជាអ្នកផ្ទេរ នូវសច្ចៈទ្រទ្រង់ នូវសេចក្ដីរីកចំរើន »។ តែបើ រៀមច្បង គាត់ រស់នៅអស់កាលជានិច្ច ជាខ្ជុំបរទេស និង គ្មាន គតិ ជាយោងគ្រប់គ្រាន់ សំរាប់ជាគំរូ នូវសច្ចៈនោះ ដែលជាការ

រៀមច្បងជាអ្នកកំសាក យុវជនជាអ្នកកម្លាច

ធានាចម្បង នៃមនុស្សធម៌ ក៏ច្បាស់ជាយុវជន បន្តរស់នៅ ជាខ្ទុំបរទេស និង មានការខកចិត្តធ្ងន់ធ្ងរបំផុត។

នៅស្រុកខ្មែរសព្វថ្ងៃ យុវជន ក្លាយជារៀមច្បង ក្នុងវេនរបស់ខ្លួន ជាអ្នកកម្លាច ព្រោះថា រៀមច្បងខ្លួន បានផ្ទេរឱ្យខ្លួន តែការកំសាកនៅចំពោះមុខ មហាវិបត្តិជាតិ ហើយនាំគ្នា លះបង់សិទ្ធខ្លួនឱ្យ អ្នកដឹកនាំ ធ្វើជាម្ចាស់ នៃវាសនា និង បន្តអត់ធ្មត់ទ្រាំទ្ររស់ សំរាប់តែរស់រស់ នៅក្នុងរបបផ្តាច់ការ។ ចំណែក អ្នកដឹកនាំ នៃគណបក្សប្រឆាំង ដែលដើរតួជារៀមច្បង ក៏ភ្ជាន បានបង្ហាញ នូវសេចក្ដីក្លាហាន ដែលជាគ្រឿ នៃការតស៊ូប្រឆាំង និងអំណាចផ្តាច់ការ ដែលជាអំណាចូបករណ៍ របស់យួន។ នៅក្នុងសភាពការណ៍បែបនេះ ស្រុកខ្មែរ មិនអាចធាត់ធំស្ថាពរបរិបូណ៌ ដោយហិទ្ធិឫទ្ធីឡើយ មុខជានឹងស្ថមស្ងិតឥតឫទ្ធិអំណាចពួកជនបរទេសទាំងឡាយ នឹងជីះជាន់ កកេរជញ្ជក់យកសាច់ឈាម នឹងក្លាយជាប្រទេសទាបទាសទុព្ធភាពមិនខាន។